BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K_1
1942 (9)

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ៩

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៥
គ.ស. ១៩៤២

# បញ្ជីរឿង

ទំព័រ


១ — វិទ្យុធម្មទេសនា កណ្ឌទី ៣ ព្រះតេជព្រះគុណ ព្រះពុទ្ធឃោសាចារ្យ (ជ. ណាត) ចាងហ្វាងរងសាលាបាលីជាន់ខ្ពស់សំដែង . . . . . . . . . . . . . . . ៣

២ — អភិនវភាសិត លោកគ្រូអាចារ្យ អ៊ុក-ជា ក្រុមជំនុំព្រះត្រៃបិដក ជាអ្នកតែង និងរៀបរៀង . . . . . . . . . . . . . . . . . . . . . . . ១២

៣ — ពង្សាវតាររោម ស្រង់យកអំពីគោលចារិកផ្សេងៗក្នុងពង្សាវតារលោក (តមក) ២១

៤ — ភូមិសាស្ត្រសង្ខេបនៃនានាប្រទេសៈ អំពីប្រទេសអង់គ្លេស (តមកនិងចប់) . . . ២៧


## រូបក្រៅរឿង


រូបក្បាច់សិលានៅក្រោមហោជាងខាងលើមាត់ទ្វារប្រាសាទសម្បូរ ( ព. ស. ១៤៣ ) . . . . . . . . . . . . . . . . . . . . . . . . ១

ធម្មទេសនាផ្សាយក្នុងវិទ្យុភ្នំពេញ

កណ្ឌទី ៣

# ព្រះពុទ្ធឃោសាចារ្យ ជួន-ណាត ចាងហ្វាងរង

# សាលាបាលីជាន់ខ្ពស់ សំដែង

នៅថ្ងៃចន្ទ ១៤ រោចខែផល្គុនឆ្នាំម្សាញ់ត្រីស័ក ព.ស. ២៤៨៤ ត្រូវនឹងថ្ងៃ ១៦ ម៉ារ្ស ១៩៤២

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស!

សូមនមស្ការចំពោះព្រះអរហំសម្មាសម្ពុទ្ធភគវន្តមុនី ព្រមទាំងព្រះសទ្ធម្មនឹងព្រះអរិយសង្ឃ!

## សូមសំដែងអំពីបុគ្គលដែលកម្រមានក្នុងលោក

ពិតជាក្នុងសកលលោកមានមនុស្សច្រើនមែន, ប៉ុន្តែបើនិយាយឲ្យឃើញជាក់ច្បាស់, ព្រះសព្វញ្ញូសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងប្រាប់ថា បុគ្គល ២ ចំពួកកម្រមានក្នុងលោក ។ បុគ្គលពីរចំពួកនោះគឺ បុព្វការី ១ កតញ្ញូ កតវេទី ១ ។

បុគ្គលណាបានទំនុកបំរុងផ្គង់ផ្គើមគេមុន នាំគេឲ្យបានលូតលាស់ចំរើន ឲ្យគេបានសេចក្តីសុខ, បុគ្គលនោះឈ្មោះថា បុព្វការី ។ បុគ្គលណាបានទទួលសេចក្តីទំនុកបំរុងនោះ ហើយដឹងគុណ បានតបឧបការគុណវិញ, បុគ្គលនោះឈ្មោះថា កតញ្ញូ កតវេទី ។

បើសំដែងដោយសាធារណៈ, តាមតែអ្នកណាក៏ដោយ ដែលបានទំនុកបំរុងគេ, អ្នកនោះហៅថា បុព្វការី; អ្នកដែលដឹងគុណ ហើយបានតបគុណវិញ ពុំគោះគើយព្រងើយ, អ្នកនោះឈ្មោះថា កតញ្ញូ កតវេទី ។ ប៉ុន្តែបើសំដែងឲ្យឃើញតាមលំអានដែលតែងតែមានពុំដែលខាននោះ, មាតាបិតាឈ្មោះថា បុព្វការី របស់បុត្រធីតា ព្រោះជាអ្នកចិញ្ចឹមបីបាច់រក្សាទំនុកបំរុងផុងផ្ដើមបុត្រប្រុសស្រី; បុត្រធីតាណា ជាអ្នកដឹងគុណ ហើយបានតបឧបការគុណចំពោះមាតាបិតា, បុត្រធីតានោះឈ្មោះថា កតញ្ញូ កតវេទី ។ លោកអ្នកប្រាជ្ញណាដែលជាសាស្តា បានប្រកាសសាសនាដ៏ល្អបរិសុទ្ធ ឬដែលបានតែងតាំងគម្ពីរក្បួនច្បាប់គម្រប់គម្រាដ៏ត្រឹមត្រូវប្រាប់ផលប្រយោជន៍ពិតៗ ទុកឲ្យអ្នកខាងក្រោយតៗមក (ដូចយ៉ាងព្រះសម្មាសម្ពុទ្ធជាដើម), លោកអ្នកប្រាជ្ញនោះឈ្មោះថា បុព្វការី របស់សាសនិកជនឬរបស់អ្នកដែលជឿស្តាប់; សាសនិកជន (ដូចយ៉ាងពុទ្ធសា-សនិកជាដើម) និងអ្នកដែលជឿស្តាប់ បានរៀនសូត្រប្រតិបត្តិកាន់តាមទៅកើតផលប្រយោជន៍ បានជួបប្រទះសេចក្តីសុខចំរើនតាមជាន់តាមថ្នាក់ ដោយសារសាសនាឬគម្ពីរក្បួនច្បាប់គម្រប់គម្រាដ៏ល្អបរិសុទ្ធត្រឹមត្រូវនោះ ហើយជាអ្នកដឹងគុណ បានតបឧបការគុណតាមដំណើរដែលត្រូវតប, អ្នកទាំងនោះឈ្មោះថា កតញ្ញូ កតវេទី ។ គ្រូអាចារ្យហៅថា

បុព្វការី របស់សិស្ស ព្រោះជាអ្នកបង្ហាត់បង្រៀនសិស្សឲ្យមានចំណេះវិជ្ជា; សិស្សដែលដឹងគុណហើយតបគុណគ្រូអាចារ្យវិញ ហៅថា កតញ្ញូ កតវេទី ។ ព្រះមហាក្សត្រជា បុព្វការី របស់ប្រជាជនក្នុងអាណាចក្រនៃព្រះអង្គ; ប្រជាជនណាជាអ្នកស្លូតត្រង់មានស្មារតីភក្តីគោរពចំពោះព្រះរាជារបស់ខ្លួន ហើយដឹងគុណ ដោយយល់ជាក់ថា ខ្លួនបានសេចក្ដីសុខចំរើនព្រោះការគ្រប់គ្រងផែនដីដែលមានព្រះមហាក្សត្រជាប្រមុខ ក៏ពេញចិត្តព្រមប្រព្រឹត្តតាមគន្លងច្បាប់សម្រាប់ផែនដី, ប្រជាជននោះឈ្មោះថា កតញ្ញូ កតវេទី ។

សូមអធិប្បាយដោយសង្ខេប:

## អំពីមាតាបិតានិងបុត្រធីតា

ក្នុងសកលលោក, បើរាប់តែចំនួនមនុស្ស, មានមាតាបិតានិងបុត្របុរសស្ត្រីច្រើនជាអនេក មិនមែនក្រទេ ព្រោះមនុស្សក្នុងលោកដែលកើតតៗគ្នាមកនោះមានច្រើនណាស់, ដែលថា ក្រមាននោះគឺ មិនសូវមានមាតាបិតានិងបុត្រធីតាដែលចេះទំនុកបំរុងសង្គ្រោះគ្នាឲ្យបានត្រឹមត្រូវតាមបែបបទ, ច្រើនតែលើសៗខ្វះៗ ត្រូវត្រង់ណេះខុសត្រង់ណោះ, បានត្រង់ណេះខ្វះត្រង់ណោះ មិនសព្វគ្រប់, ព្រោះហេតុនោះបានជាថា

កម្រមានក្នុងលោក ៗ ឯបែបបទដែលមាតាបិតាត្រូវទំនុកបំរុងបុត្រធីតា នោះមាន ៤ យ៉ាងគឺ:

១ – ចិញ្ចឹមបីបាច់រក្សាកូនដោយប្រពៃ មិនទំរើសកូនឲ្យធំចិត្ត ឲ្យឡើងតាង, កាលណាឃើញកូនធ្វើអំពើអាក្រក់ ប្រញាប់ប្រញាល់ ឃាត់ហាមហ៊ាងម៉ឺងម៉ាត់ មិនបណ្តែតបណ្តោយ, ប្រាប់ប្រដៅឲ្យស្គាល់ ទោសទុច្ចរិតដោយជាក់ស្តែង ឲ្យកូនខ្លាចរអាកងតាលរួញចិត្តគំនិតលែង ហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់នោះតទៅទៀត ៗ

២– បៀនប្រដៅកូនឲ្យរៀនកាន់សុចរិតប្រព្រឹត្តល្អតាមគន្លងធម៌ ច្បាប់, ប្រាប់ពន្យល់អំពីផលសុចរិតដោយច្បាស់លាស់ ឲ្យកូនជឿស្តាប់ ស៊ប់គំនិតពេញចិត្តស្រឡាញ់ផ្លូវត្រូវផ្លូវល្អ, បង្វឹកកូនឲ្យថ្នឹកស៊ប់ស៊ាំក្នុង ផ្លូវសុចរិត តាំងពីតូចមក ៗ

៣– ប្រដៅកូនឲ្យថ្នឹកក្នុងការចេះដឹង គឺបង្វឹកកូនឲ្យរៀនរាប់, ឲ្យ រៀនគិត, រៀនបូក, រៀនចែក, រៀនសង់, រៀនវាល់, រៀនថ្លឹង, រៀន វាស់, រៀនគ្នេរ, រៀនស្ទង់ស្ទាបការជាដើម ឲ្យថ្នឹកតាំងពីតូចមក មិន បណ្តែតបណ្តោយឲ្យកូនឆាស់តាំងគំនិតប្រាជ្ញក្នុងការចេះដឹង; លុះដល់កូន មានអាយុចំរើនធំល្មមឲ្យរៀនចំណេះវិជ្ជាហើយ បានទំនុកបំរុងឲ្យកូន រៀនអក្សរសាស្ត្រនិងវិជ្ជាផ្សេងៗតាមគួរដល់កាលៈទេសៈនិងសម័យនិយម

មិនបណ្តោយឲ្យកូនល្ងង់ទៅ (កូនទាំងប្រុសទាំងស្រីត្រូវឲ្យរៀនអក្សរជាមុន រួចសឹមឲ្យរៀនចំណេះវិជ្ជាឯទៀតៗតទៅ) ។

៤ – ត្រូវរៀបចំកូនឲ្យមានផ្ទះសំបែង តាមសមគួរដល់ពូជវង្សជាតិត្រកូលនឹងទ្រព្យធនជាដើម, ត្រូវប្រយ័ត្នកុំខាត់ការរៀបចំឲ្យហួសហេតុហួសទំនង, បើខ្លួនក្រកុំយកតម្រាប់អ្នកមាន កុំប្រណាំងប្រជែងនឹងអ្នកមានទ្រព្យ, ប្រយ័ត្នកុំឲ្យដាច់បង់ទ្រព្យធនទាល់តែដល់ថ្នាក់លក់ដីបញ្ចាំគេ ឬជំពាក់បំណុលគេរុំរោះត្រាំត្រែងយូរ, ត្រូវរៀបចំកូនឲ្យសមល្មមដល់ការគួរ កុំឲ្យទាស់ទំនង ។

៥ – ត្រូវលៃលកចំណាយប្រាក់ឲ្យកូនរៀនចំណេះវិជ្ជា, ត្រូវទិញគ្រឿងប្រដាប់ឲ្យកូនប្រើប្រាស់តាក់តែងខ្លួនខ្លះ, ឲ្យកូនមានសម្លៀកបំពាក់គ្រប់គ្រាន់, ឲ្យប្រាក់កាសចាយវាយខ្លះ មិនកំបុតកំប៉ុញហួសប្រមាណ; ក្នុងវេលាដែលចែកទ្រព្យសម្បត្តិឲ្យ ត្រូវចែកឲ្យហើយស្រេច ឲ្យត្រឹមត្រូវតាមលក្ខណៈច្បាប់, កុំទុកឱកាសឲ្យកូនឈ្លោះប្រកែកដណ្តើមរើមគ្នាជាខាងក្រោយ ។

បែបបទដែលបុត្រធីតាត្រូវគោរពត្រូវទំនុកបំរុងមាតាបិតាវិញមាន ៥ យ៉ាងគឺ:

១- ចិញ្ចឹមរក្សាមាតាបិតាដោយពេញលេញឲ្យដូចកាលមាតាបិតាចិញ្ចឹមរក្សាខ្លួន, ឬបើបានលើសជាងនោះទៅទៀតក៏រឹងរឹតតែប្រសើរណាស់ ។

២- ធ្វើកិច្ចការជំនួសមាតាបិតា, មិនតោះតើយសោះអង្គើយបណ្តែតបណ្តោយឲ្យមាតាបិតានឿយហត់ទាល់តាស់; ទោះបើខ្លួនមានស្វាមីភរិយាបែកមុខការរបរចេញឃ្លាតពីមាតាបិតាហើយ ក៏ត្រូវតែជួយធ្វើកិច្ចការរបស់មាតាបិតាតាមកាលវេលាម្តងៗដែលគួរនឹងធានពុំបាន ។

៣- តាំងរក្សាត្រកូលល្អរបស់មាតាបិតាឲ្យគង់នៅ គឺមិនបំបាត់សណ្តាប់ធ្នាប់ល្អរបស់មាតាបិតាឲ្យវិនាស, មិនប្រព្រឹត្តល្មើសរំលងធុក់ទល្អរបស់មាតាបិតា, មិនធ្វើឲ្យអ្នកមានគុណកើតទុក្ខព្រួយចិត្តព្រោះខ្លួន ។

៤- គោរពប្រតិបត្តិឲ្យល្មមមាតាបិតាពេញចិត្តឲ្យទ្រព្យសម្បត្តិកេរ្តិ៍សម្បាច់, ប្រយ័ត្នរក្សាទ្រព្យសម្បត្តិកេរ្តិ៍អាករដែលមាតាបិតាចែកឲ្យ មិនបំផ្លាញឲ្យវិនាសអសារឥតការ ។

៥- លុះឥតអំពីមាតាបិតាទៅ, បានលើកសពសំស្ការដោយគោរព, បានធ្វើទក្ខិណានុប្បទានឧទ្ទិសផលបុណ្យជូនរឿយៗ ។

មាតាបិតានិងបុត្រធីតាដែលបានបំពេញកិច្ចរបស់ខ្លួនតាមបែបបទដូចសំដែងមកនេះ ទើបពេញជាបុត្តការី កតញ្ញូ កតវេទី ត្រឹមត្រូវ;

ប៉ុន្តែច្រើនតែមិនសូវបានប្រតិបត្តិគ្រប់គ្រាន់, បានត្រង់ណេះខ្វះត្រង់ណោះ ព្រោះហេតុនោះបានជាព្រះបរមសាស្តាទ្រង់ត្រាស់សំដែងប្រាប់ថាកម្រមានក្នុងលោក ។

លំដាប់តពីនេះទៅ សូមអធិប្បាយដោយសង្ខេបខ្លីៗជាងខាងលើ បន្ទាន់តាមវេលាខ្លី ព្រោះវិទ្យុបើកឱកាសឲ្យត្រឹមតែ ១៥ នាទី ។

## អំពីសាស្តានិងសាសនិកជន

សាស្តាអស្ចារ្យដែលហៅថាអច្ឆរិយមនុស្សឬអស្ចារ្យមនុស្សដូចយ៉ាងព្រះសព្វញ្ញូសម្មាសម្ពុទ្ធ មិនមែនមានគ្រប់កាលសម័យទេ យូរៗមានម្តង, ព្រោះហេតុនោះបានជាថាកម្រមានក្នុងលោក ។ ព្រះសក្យមុនីសម្ពុទ្ធជាបរមគ្រូដើមរបស់យើង ទ្រង់មានព្រះទ័យពេញព្រៀបដោយសេចក្តីអា-ណិត ទ្រង់ចង់ឲ្យសត្វលោករួចរដោះចាកទុក្ខ; កាលព្រះអង្គជិតចូលបរិនិព្វាន ទ្រង់ខំប្រឹងឆ្លៀតប្រដៅទុកផ្តាំថា "អ្នកទាំងឡាយចូរកុំប្រ-ហែសធ្វេស!"; ដោយហេតុនេះ យើងជាពុទ្ធបរិស័ទ គួរប្រតិបត្តិកាន់តាមលំអានធម៌វិន័យពុទ្ធសាសនាដែលជាផ្លូវនាំឲ្យយើងបានប្រទះសេចក្តីសុខស្ងប់ព្រមទាំងសេចក្តីចំរើន, យើងនឹងបានឈ្មោះថា កតញ្ញូ កតវេទី ចំពោះព្រះអង្គ ។

# អំពីគ្រូអាចារ្យនឹងសិស្ស

កុំបាច់និយាយដល់គ្រូអាចារ្យដែលបង្ហាត់បង្រៀនប្រៀនប្រដៅពិតៗ, សូម្បីតែលោកអ្នកឯណា កំពុងប្រៀនប្រដៅសិស្សឬប្រៀនប្រដៅកូនចៅ ចំពោះផ្លូវធម៌នឹងច្បាប់ដ៏ត្រឹមត្រូវដែលជាពាក្យមានប្រយោជន៍គួររៀនគួរស្ដាប់, យើងបានស្ដាប់ពាក្យនោះចាំបានហើយយកមកត្រិះរិះប្រតិបត្តិតាមទៅ កើតសេចក្ដីសុខចំរើន, លោកអ្នកនោះក៏ឈ្មោះថា បុព្វការី របស់យើងដែរ, យើងត្រូវដឹងគុណហើយតបគុណកុំបំភ្លេចឲ្យសោះ យើងឈ្មោះថា កតញ្ញូ កតវេទី ។

# អំពីមហាក្សត្រនឹងប្រជាជន

ព្រះមហាក្សត្រដែលទ្រង់គ្រប់គ្រងប្រទេសនីមួយៗ ព្រះអង្គជាព្រះសម្មតិទេព "ទេវតាដោយសន្មត", ទ្រង់ព្រះនាមថា "ព្រះរាជា" ព្រោះទ្រង់ប្រកបដោយការសង្គ្រោះប្រជាជនដោយសង្គហវត្ថុ ៤ យ៉ាងគឺ ១- ប្រទានទេយ្យវត្ថុ; ២- មានព្រះវាចាគួរឲ្យចង់ឮចង់ស្ដាប់; ៣- ទ្រង់ប្រព្រឹត្តអំពើជាប្រយោជន៍; ៤- ទ្រង់តាំងព្រះអង្គស្មើៗនឹងប្រើបុកពាឲ្យល្មមពេញចិត្តប្រជាជន ។ ទ្រង់គ្រប់គ្រងប្រជាជនដោយទសពិធរាជធម៌ "ធម៌សម្រាប់ព្រះរាជាមាន ១០ យ៉ាង" គឺ ១- អំណោយទាន; ២- សក្យ

សីល ៥ ជានិច្ច; ៣– ចំណាយព្រះរាជទ្រព្យទំនុកបំរុងប្រទេស; ៤– មាន សេចក្ដីទៀងត្រង់; ៥ ទន់ភ្លន់សុភាព; ៦ – រក្សាឧបោសថសីលតាមកាល កំណត់មួយៗ; ៧ – មិនកំរោលក្រហាយប្រជាជន; ៨– មិនបៀតបៀនអ្នក ដទៃ; ៩· មានសេចក្ដីអត់ធន់; ១០ – មិនបំពានលើធម៌លើច្បាប់ ។ ដោយហេតុនេះទើបទ្រង់ព្រះនាមថា បុព្វការី របស់ប្រជាជន ។ ប្រជាជន ដែលបានសេចក្ដីសុខដោយសារការគ្រប់គ្រងរបស់ព្រះរាជា នោះហើយ ជាអ្នកដឹងឧបការគុណ ក៏តាំងចិត្តស្មូតត្រង់ចំពោះរាជការផែនដី, ជួយយក អាសាការផែនដីដោយស្មោះស្ម័គ្រ មានស្វាមីភក្ដិ៍ចំពោះព្រះរាជា ចំពោះ រាជការផែនដី ឥតមានរើងទទឹងឲ្យទាស់ផ្លូវរាជការ, យ៉ាងនេះហៅថា កតញ្ញូ កតវេទី ចំពោះព្រះរាជាជាម្ចាស់ជីវិតរបស់ខ្លួន ។

សំដែងអំពីបុព្វការីនិងកតញ្ញូ កតវេទី ដោយសង្ខេបតាមគួរដល់ វេលាខ្លី, សន្មតជាចប់ត្រឹមប៉ុណ្ណេះ ។

សុខសួស្ដីសិរីវឌ្ឍិភាពចូរមានដល់អស់លោកអ្នកស្ដាប់!

ព្រះគ្រូឋេរកសាចារ្យ ជិ. ណា.

សូមអស់លោក-អ្នកជាសប្បុរសទាំងឡាយ កំណត់ចាំទុក ហើយប្រតិបត្តិយកប្រយោជន៍ តាមគួរដល់អធ្យាស្រ័យចុះ ។ សំដែងមកដោយសង្ខេបតាមគួរដល់វេលា សន្មតថាចប់ត្រឹមប៉ុណ្ណេះ ឯវំ ។

សូមឲ្យជោគជ័យសិរីសុខគ្រប់ប្រការមានដល់អស់លោកអ្នកស្ដាប់ទាំងឡាយ អស់កាលជានិច្ចតរៀងទៅ កុំបីឃ្លាតឡើយ! ។

ព្រះបាឡាត់ឃោសនាគ អាចារ្យសាលាបាលីជាន់ខ្ពស់ ។